សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង
សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន
"គម្រោងលើកកម្ពស់មជ្ឈមណ្ឌលសិក្សាសហគមន៍នៅតាមជនបទ
ក្នុងប្រទេសកម្ពុជាដំណាក់កាលទី២"
២៤ ធ្នូ ២០១៤

- **សូមគោរព អង្គការសន្តិស្ម័គ្រចិត្ត!**
- **សូមគោរព លោក តាម៉ារិ គីយ៉ូតាកា នាយកអង្គការសន្តិស្ម័គ្រចិត្ត!**
- **សូមគោរព លោក ឈើយ ចាន់ណា ប្រធានមន្ទីរអប់រំខេត្តបន្ទាយមានជ័យ!**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនគឺ "គម្រោងលើកកម្ពស់មជ្ឈមណ្ឌលសិក្សាសហគមន៍នៅតាមជនបទក្នុងប្រទេសកម្ពុជាដំណាក់កាលទី២" ។

អង្គការសន្តិស្ម័គ្រចិត្ត (SVA) បាននិងកំពុងធ្វើការគាំទ្រដល់សកម្មភាពជាច្រើនអស់រយៈកាលជាង ៣០ឆ្នាំមកហើយក្នុងប្រទេសកម្ពុជា ហើយរដ្ឋាភិបាលជប៉ុនក៏បានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយពួកគេ។ ខ្ញុំដឹងថា វិស័យដែល(SVA) ផ្តោតជាសំខាន់នោះគឺការអប់រំ និងការអភិវឌ្ឍធនធានមនុស្ស ហើយខ្ញុំសង្ឃឹមថា គម្រោងនេះ នឹងអាចរួមចំណែកយ៉ាងធំធេងដល់ការកើនឡើងនូវអត្រានៃការចេះអាន និងសរសេរនៅតាមទីជនបទនានា។

ដោយផ្អែកលើរបាយការណ៍ជាតិរបស់ប្រទេសកម្ពុជាឆ្នាំ២០១៣ អត្រានៃការចេះអាន និងសរសេរសម្រាប់ក្មេងចាប់ពីអាយុ១៥ឆ្នាំឡើងទៅមានប្រមាណ៩០% ក្នុងទីក្រុង ហើយនៅទីជនបទមានតែ៧៦.៥% ប៉ុណ្ណោះ ហើយនៅក្នុងខេត្តបន្ទាយមានជ័យ ក៏មានអត្រាដូចគ្នា គឺ៧៦% ។ ជាពិសេស សម្រាប់នារីនៅតាមទីជនបទគឺមានអត្រាទាប ដែលបង្ហាញពីគំលាតអត្រានៃការចេះអាន និងសរសេររវាងតំបន់ទីក្រុង និងតំបន់ជនបទ ដែលឆ្លុះបញ្ចាំងពីគំលាតនៃគុណភាពជីវិត។

ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់គោលដៅនៅក្នុងផែនការយុទ្ធសាស្រ្តអប់រំសំដៅកែលម្អការអប់រំនូវការចេះអាន និងសរសេរដល់ក្មេងៗ និងមនុស្សពេញវ័យទាំងអស់។ គោលបំណង គឺដើម្បីកែលម្អបរិស្ថានអប់រំនៃការចេះអាន និងសរសេរនៅមជ្ឈមណ្ឌលសិក្សាសហគមន៍ ហើយមានទិសដៅ ដើម្បីបង្កើនមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន១០០កន្លែង គឺពី៣៧១ទៅ៤៧១កន្លែង។ គម្រោងនេះ នឹងគាំទ្រដល់គោលដៅរបស់រដ្ឋាភិបាល។

គម្រោងក្នុងឆ្នាំទី១ បានទទួលជោគជ័យក្នុងការសាងសង់មជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន២កន្លែង ក្នុងឃុំនីពេជ្រ ខេត្តកំពង់ធំ និងក្នុងឃុំរុងក ខេត្តសៀមរាប។ គម្រោងក្នុងឆ្នាំទី២ នឹងធ្វើក្នុងឃុំគោកបល្ល័ង្គ និងឃុំអូរប្រាសាទ ខេត្តបន្ទាយមានជ័យ ហើយនឹងសាងសង់មជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន២ សម្រាប់បង្រៀនដល់ប្រជាពលរដ្ឋប្រមាណជា២២,៥០០នាក់ក្នុងសហគមន៍ ដើម្បីកែលម្អបំណិននៃការចេះអាន និងសរសេរ និងគិតលេខ ព្រមទាំងការងារផ្សព្វផ្សាយ ដើម្បីទាក់ទាញមនុស្សអោយចូលរួមកាន់តែច្រើន។

ជាចុងក្រោយនេះ ជំនួយឧបត្ថម្ភឥតសំណង សម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ត្រូវបានផ្តល់ជូនសម្រាប់គម្រោងអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ច ដែលត្រូវបានអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលជប៉ុន និងផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់ប្រជាពលរដ្ឋនៅតាមថ្នាក់មូលដ្ឋាន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា មជ្ឈមណ្ឌលអប់រំសហគមន៍ ដែលត្រូវបានសាងសង់ដោយគម្រោងនេះ នឹងត្រូវបានថែទាំអោយបានត្រឹមត្រូវ ថែរក្សាអោយបានគង់វង្សយូរអង្វែង និង ផ្តល់គុណប្រយោជន៍ដល់ប្រជាជនជាច្រើនតាមដែលអាចទៅបាន។ **សូមអរគុណ!**